**សន្ទរកថាស្វាគមន៍**

**ដោយ**

**ឯកឧត្តម ត្រាំ អ៊ីវតឹក**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា**

**ក្នុង**

**ពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ និង កិច្ចប្រជុំពាក់ព័ន្ធ**

**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧**

**ខេត្តសៀមរាប**

- *សូមគោរព **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់*
- ***ឯកឧត្តម** HuoLin Zhao, អគ្គលេខាធិការនៃសភាពទូរគមនាគមន៍អន្តរជាតិ (ITU)*
- *ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រីនៃប្រទេសសមាជិកអាស៊ាន និងប្រទេសដៃគូសន្ទនាទាំងអស់*
- ***ឯកឧត្តមបណ្ឌិត** Lim Hon Hin អគ្គលេខាធិការរងអាស៊ាន*
- *ឯកឧត្តម  លោកជំទាវគណៈប្រតិភូ, ភ្ញៀវជាតិ និងអន្តរជាតិ*
- *លោក លោកស្រីទាំងអស់!*

ក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូល

រួមជាអធិតីក្នុងពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធ (TELMIN17) ក្នុងថ្ងៃនេះ។

កាលពីដប់ឆ្នាំមុន ខេត្តសៀមរាបធ្លាប់ទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ានលើកទី៧រួចម្តងហើយ។ ខ្ញុំជឿជាក់ថា សហការីនិងគណៈប្រតិភូមួយចំនួន ដែលមានវត្តមាននៅទីនេះ ក៏ធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំនោះផងដែរ។ នៅពេលនោះ ស្ថិតនៅក្រោមប្រធានបទ **"បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានៈ ឆ្ពោះទៅកាន់ទីជនបទ"** យើងបានពិភាក្សាផ្លាស់ប្តូរយោបល់អំពីការជំរុញការបង្កើនហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដល់ទីជនបទ តាមរយៈការបង្កើតសកម្មភាពនិងមធ្យោបាយនានា ដើម្បីជានាក្នុងការផ្តល់សេវាទូរគមនាគមន៍ និងបច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មាន ឱ្យបានស្មើភាព និងតម្លៃសមរម្យដល់សហគមន៍ជនបទ និងតំបន់ដាច់ស្រយាល ព្រមទាំងជំរុញការទទួលខុសត្រូវសង្គមរបស់ក្រសួង ស្ថាប័ន អង្គភាព អង្គការអន្តរជាតិ វិស័យឯកជន និងបុគ្គលពាក់ព័ន្ធផ្សេងទៀតក្នុងសង្គមព័ត៌មានវិទ្យា។

នៅឆ្នាំនេះ យើងកំណត់យកប្រធានបទ **"សន្ទិភាព និងកម្មញ្ញភាពវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានៈ ឆ្ពោះទៅសហគមន៍មួយដែលត្រូវបានធ្វើសមាហរណកម្មឌីជីថល"** ដោយហេតុថាយើងចង់ឱ្យមានការប្រែក្លាយដោយរលូនមួយក្នុងការឈានទៅកសាងសេដ្ឋកិច្ចដែលទ្រទ្រង់ដោយបច្ចេកវិទ្យាឌីជីថល ដោយផ្តោតលើប្រធានបទគោល និងសំខាន់ៗជាច្រើន ជាអាទិ៍ **ការបង្កើនការតភ្ជាប់នៅក្នុងតំបន់, ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅក្នុងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម, ការបណ្តុះបណ្តាលវានុវត្តន៍ ការច្នៃប្រឌិត និងសហគ្រិនភាព, ការបង្កើនសន្តិសុខព័ត៌មានវិទ្យា និងការគ្រប់គ្រងទិន្នន័យឌីជីថល ព្រមទាំងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅក្នុងទីផ្សាររួមអាស៊ាន (ASEAN Single Market)**។

មួយវិញទៀតនិងកាន់តែជាក់ច្បាស់ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ នេះ រដ្ឋមន្ត្រីអាស៊ានទាំងអស់ នឹងផ្លាស់ប្តូរយោបល់គ្នាលើការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងពិភាក្សាលើរបាយការណ៍របស់កិច្ចប្រជុំឧត្តមមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន លើចំណុចមួយចំនួន ដូចជា ដំណើរការវិវត្តន៍និងសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០១៧ ដែលរួមមានៈ ការលើកជាអនុសាសន៍របស់កិច្ចប្រជុំឧត្តមមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន និងការពិនិត្យចុងក្រោយលើយុទ្ធសាស្ត្រស្តីពីកិច្ចសហ-ប្រតិបត្តិការសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន, របាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមប្រឹក្សានិយ័តករទូរគមនាគមន៍អាស៊ាន, ការអនុវត្តសកម្មភាពការងារវិលជុំឆ្នាំ២០១៧ និងលទ្ធផលរបស់ខ្លួន,

តួលេខសូចនាករនៃអនុវត្តចម្បងៗ (KPI) សម្រាប់ធ្វើការវាយតម្លៃសមិទ្ធផលសម្រេចបានផ្អែកតាមគោលបំណងនៃផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ានឆ្នាំ២០២០, និងស្ថានភាពនៃមូលនិធិបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន និងគម្រោងថវិកាសម្រាប់ការអនុវត្តផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន ឆ្នាំ២០២០។

ជាងនេះទៅទៀត រដ្ឋមន្ត្រីអាស៊ាននឹងជួបពិភាក្សាផ្លាស់ប្តូរយោបល់គ្នាជាមួយនឹងរដ្ឋមន្ត្រីមកពីដៃគូសន្ទនានិងអគ្គលេខាធិការនៃសហភាពទូរគមនាគមន៍អន្តរជាតិ ស្តីពីបញ្ហានិង/ឬកិច្ចព្រមព្រៀងដែលមាន ក្នុងកិច្ចសហប្រតិបត្តិការជាមួយភាគីខាងក្រៅ រួមមានសំណើ និង/ឬផែនការការងារដែលបានស្នើឡើងដោយដៃគូសន្ទនានិងសហភាពទូរគមនាគមន៍អន្តរជាតិ។

ជាទីបញ្ចប់ ក្នុងនាមអង្គកម្មវិធីទាំងមូល ខ្ញុំបាទសូមគោរពជូនពរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកបដោយសុខភាពល្អ សុភមង្គល និងជោគជ័យក្នុងបេសកកម្មបម្រើជាតិ និងប្រជាជន។

ខ្ញុំក៏សូមគោរពជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលមានវត្តមាននៅទីនេះ ឱ្យប្រកបដោយសុខភាពល្អ សុភមង្គល និងជោគជ័យក្នុងកិច្ចការងារ។

*សូមគោរពថ្លែងអំណរគុណ និងសូមអរគុណ។*